# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

*ភ្នំពេញ ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១*

## លិខិតចំហ

យើងខ្ញុំទាំងអស់គ្នាជាកសិករ សហគមន៍រងគ្រោះដីធ្លី ប្រជានេសាទ កម្មករ អ្នកប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជនជាតិដើមភាគតិច សហជីព និងសង្គមស៊ីវិល

## <u>ជូនចំពោះ</u>
## តំណាងនៃអង្គការស្បៀងអាហារ និងកសិកម្មប្រចាំប្រទេសកម្ពុជា

**កម្មវត្ថុ៖** ស្នើសុំដោះស្រាយនូវបញ្ហាប្រឈម ក្ដីកង្វល់ និងតម្រូវការរបស់កសិករ សហគមន៍រងគ្រោះដីធ្លីប្រជានេសាទ កម្មករ អ្នកប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជនជាតិដើមភាគតិច សហជីព និងសង្គមស៊ីវិលនៅក្នុងកិច្ចប្រជុំកំពូលថ្នាក់ជាតិ និងសកលស្តីពីប្រព័ន្ធស្បៀងអាហាររបស់អង្គការសហប្រជាជាតិ។

នៅខែកញ្ញា ឆ្នាំ២០២១ ខាងមុខនេះ អង្គការសហប្រជាជាតិនឹងរៀបចំកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារ ក្នុងគោលបំណងបង្កើនចំណីអាហារ និងកសិកម្ម ដើម្បីពន្លឿនគោលដៅអភិវឌ្ឍន៍សហសវត្សន៍ប្រកបដោយចីរភាព ដើម្បី «ផ្លាស់ប្ដូរប្រព័ន្ធស្បៀងអាហារ» ឆ្ពោះទៅរក «របបអាហារដែលមានសុខុមាលភាព ចីរភាព និងរស់នៅប្រកបដោយសុភមង្គល» និងការពារភពផែនដីរបស់យើង។

ទោះជាយ៉ាងណា គោលគំនិត និងដំណើរការនៃកិច្ចប្រជុំកំពូលរបស់អង្គការសហប្រជាជាតិកំពុងបង្ហាញឱ្យឃើញនូវការបន្តផ្សព្វផ្សាយ និងការចែកចាយនូវរបៀបវារៈ ដែលជំរុញដោយវេទិកាសេដ្ឋកិច្ចពិភពលោក និងដៃគូក្រុមហ៊ុនសាជីវកម្មដែលស្ថិតជាមួយរដ្ឋាភិបាល ហើយប្រើប្រាស់ប្រព័ន្ធសេដ្ឋកិច្ចសេរីភាវូបនីយកម្មបែបថ្មីដែលជះឥទ្ធិពលអវិជ្ជមានដល់ដំណើរការសម្រេចចិត្តរបស់កសិករ ប្រជានេសាទ កម្មករ អ្នកប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជនជាតិដើមភាគតិច។ នេះជាគំរូថ្មី និងដំណើរការផ្លាស់ប្ដូរប្រព័ន្ធស្បៀងអាហារ ធ្វើឱ្យក្រុមហ៊ុនសាជីវកម្មទាញយកផលចំណេញ និងអំណាចសេដ្ឋកិច្ចជាចម្បង។ កត្តាទាំង

នេះ បណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិរបស់យើង អាកាសធាតុរបស់យើង និងអនាគតរបស់យើងនៅគ្រប់ទិសទីកន្លែង។

យើងខ្ញុំសូមសម្តែងនូវក្តីកង្វល់យ៉ាងខ្លាំងចំពោះភាពអត់ឃ្លានដែលអាចនឹងកើនឡើងយ៉ាងលឿនជាងការឆ្លងជំងឺកូវីត១៩។ តាមការប៉ាន់ប្រមាណមួយបង្ហាញថា អាចនឹងមានផលប៉ះពាល់ដល់អាយុជីវិតច្រើនជាងការឆ្លងរីករាលដាលនៃជំងឺរាតត្បាតនេះទៅទៀត។ ជាក់ស្តែង ចំនួនមនុស្សបានជួបប្រទះនឹងភាពអត់ឃ្លានធ្ងន់ធ្ងរដែលបានកើនឡើងទ្វេដង នៅឆ្នាំ២០២០។ ពួកគេចូលដំណេកដោយគ្មានអាហារទទួលទានកាន់តែច្រើនឡើងៗ។ វិបត្តិស្បៀងអាហារពិភពលោកមិនដែលកើតមាន និងឈានដល់កម្រិតខ្ពស់ នាពាក់កណ្តាលសតវត្សរ៍ចុងក្រោយនេះ។

ជាការពិត វិបត្តិនៃភាពអត់ឃ្លានសព្វថ្ងៃនេះ គឺជាលទ្ធផលកើតចេញពីប្រព័ន្ធស្បៀងអាហារ និងកសិកម្មដែលមានលក្ខណៈផុយស្រួយ ដែលគិតតែពីការរកផលចំណេញ។ ការធ្វើពាណិជ្ជកម្មកសិកម្ម និងស្បៀងអាហារក្នុងស្រុក និងអន្តរជាតិ ជាកម្លាំងចលករ និងជំរុញឱ្យមានការរឹបអូសយកដីធ្លី និងការកេងប្រវ័ញ្ចធនធានធម្មជាតិ។ ការអនុវត្តក្របខ័ណ្ឌសេរីភាវូបនីយកម្មថ្មីក្នុងវិស័យនេះអស់ជាច្រើនទសវត្សរ៍ដែលបានបង្កើតឱ្យមានគម្លាតដ៏ធំធេងរវាងអ្នកមាន និងអ្នកក្រ ឬ ប្រទេសអ្នកមាន និងប្រទេសអ្នកក្រ។ ជាពិសេស បណ្តាលឱ្យមានភាពក្រីក្រកាន់តែខ្លាំងឡើងៗដល់អ្នកផលិតស្បៀងអាហារនៅក្នុងតំបន់លោកខាងត្បូង។ ភាពអត់ឃ្លានបានកើនឡើងអស់ជាច្រើនឆ្នាំជាប់ៗគ្នា ខណៈដែលមានកំណត់ត្រានៃការប្រមូលផលកសិកម្មបានយ៉ាងច្រើនពីដំណាំចម្បងៗ, ការដឹកជញ្ជូនចែកចាយស្បៀងអាហារកំពុងកើនឡើង និងមានភាពសម្បូរបែបនៃស្បៀងអាហារ។

ទិដ្ឋភាពជាក់ស្តែងមួយចំនួនអំពីភាពអត់ឃ្លាននៅកម្ពុជារួមមាន អស្ថិរភាពនយោបាយបានរួមចំណែកធ្វើឱ្យមានការថយចុះធនធានធម្មជាតិ, កង្វះអាហារូបត្ថម្ភមានប្រមាណ១៥% ដែលស្មើនឹងប្រជាពលរដ្ឋជាង ២លាននាក់, មានប្រជាពលរដ្ឋប្រមាណ ៧៩% រស់នៅតាមតំបន់ជនបទពឹងផ្អែកលើកិច្ចការកសិកម្ម ជលផល និងព្រៃឈើ ដើម្បីរស់រានមានជីវិត។ ជារឿយៗ ពួកគេរងការគំរាមកំហែង និងត្រូវរងការបំផ្លាញប្រព័ន្ធស្បៀងអាហារ។ គ្រួសារកសិករនៅជនបទត្រូវបានប៉ាន់ប្រមាណថាមាន ១,៦ លានគ្រួសារដែលរងកង្វះខាតស្រូវតាមរដូវកាល ហើយការចំណាយរបស់ពួកគេប្រមាណ ៣០% ក្នុងគ្រួសារនីមួយៗ

ដែលពឹងលើផលិតផល ស្រូវ។ រីឯ កុមារកម្ពុជាប្រមាណ ៤០% បានទទួលរងពីកង្វះអាហារូបត្ថម្ភ និងជម្ងឺក្រិនរ៉ាំរ៉ៃ[1]។

លើសពីនេះទៀត ប្រមាណ ៤០% នៃកសិករ ៩៨ គ្រួសារ នៅក្នុងខេត្តចំនួន៧ រួមមានខេត្តកំពង់ឆ្នាំង កំពុងស្ពឺ ព្រះសីហនុ ត្បូងឃ្មុំ ក្រចេះ និងខេត្តព្រះវិហារ ដែលបានសម្ភាសន៍មានជំពាក់បំណុលធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដោយសារតម្រូវការលើផលិតកម្មកសិកម្ម ហើយពួកគេកំពុងប្រឈមនឹងបញ្ហាក្នុងការសងបំណុលនៅក្នុងអំឡុងពេលវិបត្តិកូវីត ១៩។ កសិករធ្វើស្រែ ចិញ្ចឹមសត្វ និងដាំដំណាំកសិផលផ្សេងៗទៀតពឹងផ្អែកលើទឹកភ្លៀង និងធម្មជាតិទាំងស្រុង ដោយសារតែមិនមានប្រព័ន្ធទឹកសម្រាប់ស្រោចស្រព ជាពិសេសនៅរដូវប្រាំង។ បម្រែបម្រួលអាកាសធាតុ (ភាពរាំងស្ងួត និងទឹកជំនន់)និងការផ្លាស់ប្តូររបបទឹកភ្លៀងលែងត្រូវតាមរដូវកាល គឺជាឧបសគ្គយ៉ាងធំធេងសម្រាប់កសិករ។ បញ្ហាទាំងនេះបានបំផ្លាញកសិផល ធ្វើឲ្យកសិករខ្នាតតូច និងជនជាតិដើមភាគតិចមិនមានលទ្ធភាពឆ្លើយតបទៅនឹងវិបត្តិធម្មជាតិ និងបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ ស្របពេលដែលការទទួលខុសត្រូវសង្គមពីអាជ្ញាធររដ្ឋ នៅមានភាពខ្វះចន្លោះ។ បន្លែ ត្រី និងសាច់ភាគច្រើន ត្រូវនាំយកទៅលក់នៅក្រៅប្រទេស ហើយការផ្គត់ផ្គង់ស្បៀងអាហារនៅមូលដ្ឋានភាគច្រើន ត្រូវបាននាំចូលពីក្រៅប្រទេស ដែលជាអាហារមិនមានប្រភពច្បាស់លាស់ ឬ ការត្រួតពិនិត្យផលប៉ះពាល់សុខភាព។ បញ្ហាកង្វះស្បៀងអាហារ បណ្តាលឱ្យកសិករភាគច្រើនត្រូវចំណាកស្រុកដើម្បីលក់កម្លាំងពលកម្ម ហើយសន្សំប្រាក់សម្រាប់ទិញស្បៀងអាហារ និងផ្គត់ផ្គង់តម្រូវការចាំបាច់ផ្សេងៗក្នុងគ្រួសារ។ ដីធ្លីសម្រាប់កសិកម្មរបស់កសិករមិនមានសុវត្ថិភាព និងងាយបាត់បង់ ដោយសារការបន្តរំលោភបំពានពីពួកអ្នកមានអំណាច និងគម្រោងអភិវឌ្ឍន៍នានារបស់ក្រុមហ៊ុនសាជីវកម្មកសិឧស្សាហ៍កម្ម ការរុករ៉ែ និងការយកដីធ្លីធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានារបស់អាជ្ញាធររដ្ឋជាដើម[2]។

ហេតុផលខាងលើបានបង្ហាញយ៉ាងច្បាស់ពីប្រព័ន្ធស្បៀងអាហារដែលមានភាពអយុត្តិធម៌ វិសមភាព មិនមានសុខុមាលភាព និងអចីរភាព បណ្តាលមកពីភាពផ្តាច់មុខទាំងក្នុងប្រទេស តំបន់ និងនៅលើពិភពលោក។ ផលិតកម្ម និងការធ្វើពាណិជ្ជកម្មលើវិស័យកសិកម្មនេះ បានជំរុញឱ្យមានការរឹបអូសយកដីធ្លី និងការបំផ្លាញបរិស្ថាន អស់ជាច្រើនទសវត្សរ៍។ កត្តានេះត្រូវបានគាំទ្រពីសន្ធិសញ្ញា និងកិច្ចព្រមព្រៀងនានា

---

[1] Emma Benson, 5 facts about hunger in Cambodia, June 30, 2020.

[2] ថ្ងៃទី២០ ដល់ ២៣ ខែកក្កដា ឆ្នាំ២០២១ របាយការណ៍សិក្សាស្រាវជ្រាវជាមួយកសិករលើប្រព័ន្ធស្បៀងអាហារនៅកម្ពុជាបច្ចុប្បន្ន។

នៅក្រោមអង្គការពាណិជ្ជកម្មពិភពលោក និងក្រុមហ៊ុនអន្តរជាតិដទៃទៀត។ ពួកដង្កៅធំៗគ្រប់គ្រងដីធ្លី និងពាណិជ្ជកម្មលើវិស័យកសិកម្ម ខណៈដែលអ្នកផលិតស្បៀងអាហារតូចតាច ប្រជានេសាទ កម្មករ អ្នកប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ ជនជាតិដើមភាគតិច និងប្រជាពលរដ្ឋនៅជនបទ បានបង្កើនការចំណាយ ហើយបានធ្លាក់ទៅក្នុងវិបត្តិបំណុល និងភាពអត់ឃ្លាន។

ជាចុងក្រោយ សិទ្ធិរបស់កសិករចំពោះការកាន់កាប់ដីធ្លី និងការប្រើប្រាស់ធនធាន សិទ្ធិកសិករចំពោះការអភិវឌ្ឍ និងការសម្រេចចិត្តដោយខ្លួនឯង នៅតែអវត្តមាន និងមិនត្រូវបានគេរំលេចឡើងនៅក្នុងឯកសារកិច្ចប្រជុំកំពូលនានា។ ប្រសិនបើ តម្រូវការរបស់កសិករតូចតាច ប្រជានេសាទ កម្មករ អ្នកប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជនជាតិដើមភាគតិច មិនត្រូវបានយកចិត្តដាក់បញ្ចូលទៅក្នុងកិច្ចប្រជុំកំពូលថ្នាក់ជាតិ និងអន្តរជាតិ ពួកយើងនឹងមិនអាចទទួលបានយុត្តិធម៌ សមធម៌ សុខុមាលភាព និងចីរភាពនៃប្រព័ន្ធស្បៀងអាហារឡើយ។

ដូច្នេះ ការស្តារឡើងវិញនូវប្រព័ន្ធស្បៀងអាហារប្រកបដោយយុត្តិធម៌ សមធម៌ សុខុមាលភាព និងចីរភាព ត្រូវការផ្លាស់ប្តូរយ៉ាងធំធេង ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងសេចក្តីប៉ងប្រាថ្នា ព្រមទាំងឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុ។ យើងខ្ញុំសូមស្នើដល់អង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា និងអន្តរជាតិដែលដឹកនាំកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហាររបស់អង្គការសហប្រជាជាតិនាពេលខាងមុខ ដោយសូមលើកជូននូវដំណោះស្រាយចាំបាច់មួយចំនួនដូចខាងក្រោម៖

- អនុសាសន៍ជូនចំពោះកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហាររបស់អង្គការសហប្រជាជាតិ៖
  ១. បដិសេធចំពោះការជ្រៀតជ្រែកឥទ្ធិពលរបស់ក្រុមហ៊ុនសាជីវកម្មនៅក្នុងកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារ នាខែកញ្ញា ឆ្នាំ២០២១។
  ២. បញ្ចប់ការត្រួតត្រារបស់ក្រុមហ៊ុនសាជីវកម្មលើផ្នែកកសិកម្ម និងប្រព័ន្ធស្បៀងអាហារ តាមរយៈការបញ្ឈប់ភាពជាដៃគូរវាងកិច្ចប្រជុំកំពូលស្តីពីប្រព័ន្ធស្បៀងអាហារ ជាមួយវេទិកាសេដ្ឋកិច្ចពិភពលោក។
  ៣. លើកកម្ពស់អធិបតេយ្យស្បៀងអាហាររបស់កសិករ ប្រជានេសាទ កម្មករ អ្នកប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជនជាតិដើមភាគតិច ជាជាងការផ្តល់ឱកាសឱ្យក្រុមហ៊ុនសាជីវកម្ម។

➢ អនុសាសន៍ជូនចំពោះអង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា

១. ស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រខ្នាតតូច និងមធ្យមសមស្របដែលមិនប៉ះពាល់បរិស្ថានធម្មជាតិ។ កត្តានេះត្រូវការចំបាច់ និងបន្ទាន់សម្រាប់ដោះស្រាយកង្វះខាតទឹកស្រោចស្រពកសិកម្មនៅតាមសហគមន៍ ដើម្បីឱ្យកសិករមានលទ្ធភាពបង្កបង្កើនផល ការផលិតស្បៀងអាហារ និងការអភិវឌ្ឍសហគមន៍ប្រកបដោយចីរភាព។

២. ថ្វីត្បិត ប្រទេសកម្ពុជាបើកចំហដើងមេឃសេដ្ឋកិច្ចតាមយន្តការសេរីភាវូបនីយកម្ម តែត្រូវតែមានការត្រួតពិនិត្យត្រឹមត្រូវ ប្រកបដោយតម្លាភាព ដើម្បីកុំឱ្យមានការនាំចូលផលិតផលស្បៀងដែលគ្មានគុណភាពបណ្តាលឱ្យប៉ះពាល់ដល់សុខភាព និងផលិតផលអាហារដែលគ្មានប្រយោជន៍ផ្នែកអាហាររូបត្ថម្ភ។ ពង្រឹងសមត្ថភាព និងផ្តល់បរិយាកាសសមស្របឱ្យកសិករអាចផលិត និងទទួលបានអាហារប្រកបដោយគុណភាព និងអាហាររូបត្ថម្ភខ្ពស់ ដោយត្រូវចូលរួមគាំទ្រដល់ការពង្រឹងផលិតកសិផល និងការលក់ដូរក្នុងមូលដ្ឋាន ដើម្បីបម្រើសេចក្តីត្រូវការរបស់សហគមន៍ជា ចម្បង។

៣. កាត់បន្ថយការគាំទ្រដល់ក្រុមហ៊ុនសាជីវកម្មកសិឧស្សាហ៍កម្មធំៗ ដែលបង្កើតវប្បធម៌ដាំដុះកសិ-ឧស្សាហ៍កម្មមួយមុខ ហើយមិនអាចបម្រើដល់វិស័យស្បៀងអាហារ និងអាហាររូបត្ថម្ភសម្រាប់ប្រជាពលរដ្ឋ ព្រមទាំងបំផ្លាញបរិស្ថានធម្មជាតិ ធនធានទឹក និងកាត់បន្ថយគម្របព្រៃឈើធម្មជាតិយ៉ាងធ្ងន់ធ្ងរសព្វថ្ងៃនេះ។ តាមរយៈនេះ ត្រូវពង្រីកការផ្សព្វផ្សាយអំពីការថែរក្សាគ្រាប់ពូជប្រពៃណី និងលើកកម្ពស់ការចែករំលែកគ្រាប់ពូជប្រពៃណី និងចំណេះដឹងរវាងសហគមន៍ និងសហគមន៍។

៤. លើកកម្ពស់ការគោរពសិទ្ធិកសិករខ្នាតតូច ប្រជានេសាទ កម្មករ អ្នកប្រកបមុខរបរសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងជនជាតិដើមភាគតិច ដែលជាអ្នកផលិតស្បៀងអាហារ ដោយពង្រឹងបច្ចេកវិទ្យាផលិតកម្មកសិកម្មសមស្រប, កសិកម្មប្រកបដោយចីរភាពមិនប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម និងកសិកម្មអភិរក្ស (កសិកម្មបែបក្សេត្របរិស្ថាន) ដែលធានាដល់ការការពារធនធានធម្មជាតិ និងបរិស្ថានធម្មជាតិ ព្រមទាំងពង្រឹងប្រព័ន្ធស្បៀងអាហារដែលមានយុត្តិធម៌ សមធម៌ សុខុមាលភាព និងចីរភាពសម្រាប់សង្គមកម្ពុជាទាំងមូល។

យើងខ្ញុំទាំងអស់គ្នារីករាយសហការណ៍ក្នុងការផ្តល់ព័ត៌មានលំអិត និងខ្លឹមសារទាំងឡាយដែលមានចែងក្នុងលិខិតខាលើនេះ។ ដើម្បីទទួលបានព័ត៌មានលំអិតបន្ថែម សូមទំនាក់ទំនងមកកាន់ក្រុមការងាររៀបចំ៖


- **ប៉ឹក សោភ័ណ** នាយកប្រតិបត្តិនៃអង្គការពន្លកខ្មែរ

  ទូរស័ព្ទលេខ៖ ០១៥ ៦៣៨ ១៧១

- **កែវ ចាន់រ៉ា** លេខាធិការនៃសម្ព័ន្ធប្រជាពលរដ្ឋដើម្បីអធិបតេយ្យស្បៀងអាហារប្រចាំនៅតំបន់អាស៊ី
  ទូរស័ព្ទលេខៈ ០៧៧ ៥៥៣ ២១១
- **ទឹម ម៉ាឡៃ** អ្នកសម្របសម្រួលនៃផ្ទះសាមគ្គី
  ទូរស័ព្ទលេខៈ ០១៧ ៩៩០ ៦៨៩
- **អ៊ុល វ៉ាន់** ប្រធានសមាគមបណ្តាញយុវជនកម្ពុជា
  ទូរស័ព្ទលេខៈ ០៩៣ ៩១៣ ០១១

**សូមភ្ជាប់ជាមួយនូវបញ្ជីរាយនាមស្ថាប័នដែលចូលរួមគាំទ្រ៖**

| | |
|---|---|
| ១. កម្មវិធីសប្បុរសធម៌កម្ពុជា | (ក.ស.ក) |
| ២. ក្លឹមមិត្តអ្នកអាន | (FRC) |
| ៣. បណ្តាញសហគមន៍ព្រៃឈើ | ខេត្តព្រះវិហារ |
| ៤. បណ្តាញសហគមន៍ជនជាតិដើមភាគតិច | ខេត្តព្រះវិហារ |
| ៥. បណ្តាញម្លូព្រៃ (ស្លុរអំពៅ) | ខេត្តព្រះវិហារ |
| ៦. បណ្តាញយុវជន និងបណ្តាញសង្គម | ខេត្តព្រះវិហារ |
| ៧. បណ្តាញសហគមន៍ដើម្បីសកម្មភាព | ខេត្តព្រះវិហារ |
| ៨. បណ្តាញសហគមន៍ព្រៃព្រះរកា | ខេត្តព្រះវិហារ |
| ៩. បណ្តាញសហគមន៍កសិកម្មប្រតិបត្តិល្អ | ខេត្តព្រះវិហារ |
| ១០. មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស | (សង់ត្រាល់) |
| ១១. មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព | (ភីឌីភី) |
| ១២. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | (CCHR) |
| ១៣. សហគមន៍ព្រែកតាគង់៦០ម៉ែត្រ | ភ្នំពេញ |
| ១៤. សហគមន៍ ៩២ | ភ្នំពេញ |
| ១៥. សហគមន៍ចំរើន | ភ្នំពេញ |
| ១៦. សហគមន៍ស្នេសាន្ត | ភ្នំពេញ |
| ១៧. សហគមន៍ឬស្សីស្រស់ | ភ្នំពេញ |
| ១៨. សហគមន៍ស្ទឹងកំបុត | ភ្នំពេញ |
| ១៩. សហគមន៍ភូមិ២៣ | ភ្នំពេញ |
| ២០. សហគមន៍ផ្លូវរថភ្លើង | ភ្នំពេញ |

| | |
|---|---|
| ២១. សហគមន៍ទួលសង្កែអេ | ភ្នំពេញ |
| ២២. សហគមន៍ដីធ្លីអណ្តូងត្របែក | ខេត្តស្វាយរៀង |
| ២៣. សហគមន៍សាមគ្គីមោសហែក | ខេត្តស្វាយរៀង |
| ២៤. សហគម៏មានជ័យ | ខេត្តស្វាយរៀង |
| ២៥. សហគមន៍ចេកមាស | ខេត្តស្វាយរៀង |
| ២៦. សហគមន៍អមលាំង | ខេត្តកំពង់ស្ពឺ |
| ២៧. សហគមន៍ត្រពាំងដោ | ខេត្តកំពង់ស្ពឺ |
| ២៨. សហគមន៍ស្មើសាមគ្គី | ខេត្តកំពង់ស្ពឺ |
| ២៩. សហគមន៍ចំបក់ត្រាង | ខេត្តកំពង់ស្ពឺ |
| ៣០. សហគមន៍ដកពរ | ខេត្តកំពង់ស្ពឺ |
| ៣១. សហគមន៍ពាមរស់ | ខេត្តកំពង់ស្ពឺ |
| ៣២. សហគមន៍ការពារសិទ្ធិដីធ្លី ១៩៧ | ខេត្តកោះកុង |
| ៣៣. សហគមន៍ក្រីក្រ ៧៦៦ | ខេត្តកោះកុង |
| ៣៤. សហគមន៍ដីធ្លី ១៧៥ | ខេត្តកោះកុង |
| ៣៥. សហគមន៍ដីធ្លី ១២៩ | ខេត្តកោះកុង |
| ៣៦. សហគមន៍ដីធ្លី ១៤៣ | ខេត្តកោះកុង |
| ៣៧. សហគមន៍ដីធ្លីតានួន | ខេត្តកោះកុង |
| ៣៨. សហគមន៍ជនជាតិដើមភាគតិចអារ៉ែង | ខេត្តកោះកុង |
| ៣៩. សហគមន៍ដីធ្លីជីខក្រោម | ខេត្តកោះកុង |
| ៤០. សហគមន៍ដីធ្លីជីខលើ | ខេត្តកោះកុង |
| ៤១. សហគមន៍ឃ្លាំងទឹក៧៨ | ខេត្តសៀមរាប |
| ៤២. សហគមន៍ភ្នំក្រោម | ខេត្តសៀមរាប |
| ៤៣. សហគមន៍ដីធ្លី | ខេត្តប៉ៃលិន |
| ៤៤. សហគមន៍អូរល្លីព្រេង | ខេត្តបាត់ដំបង |
| ៤៥. សហគមន៍ដីធ្លីព្រៃពាយ | ខេត្តកំពត |
| ៤៦. សហគមន៍ព្រៃឈើពេជ្រចង្វារល្អធើត | ខេត្តកំពង់ឆ្នាំង |
| ៤៧. សហគមន៍ឡពាំង | ខេត្តកំពង់ឆ្នាំង |
| ៤៨. សហគមន៍ស្រែប្រាំង | ខេត្តត្បូងឃ្មុំ |
| ៤៩. សហគមន៍ដាំក្រវៀន | ខេត្តត្បូងឃ្មុំ |

| | |
|---|---|
| ៥០. សហគមន៍ថ្មដា | ខេត្តពោធិ៍សាត់ |
| ៥១. សហគមន៍ព្រៃឈើអូរកក់ | ខេត្តក្រចេះ |
| ៥២. សហគមន៍ព្រៃឈើវាលកន្សែង | ខេត្តក្រចេះ |
| ៥៣. សហគមន៍ព្រៃឈើភ្នំសេះ | ខេត្តក្រចេះ |
| ៥៤. សហគមន៍ព្រៃឈើភ្នំបាក់ | ខេត្តក្រចេះ |
| ៥៥. សហគមន៍ជនជាតិដើមភាគតិច ចារ៉ាយ | ខេត្តរតនគិរី |
| ៥៦. សហគមន៍ទ្រទ្រង់ធម្មជាតិ | ខេត្តពោធិ៍សាត់ |
| ៥៧. សមាគមបណ្ដាញយុវជនកម្ពុជា | ( CYN ) |
| ៥៨. សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា | ( CCFC ) |
| ៥៩. សមាគមមន្ត្រីរាជការឯករាជ្យកម្ពុជា | ( CICA ) |
| ៦០. សម្ព័ន្ធប្រជាជនដើម្បីអធិបតេយ្យស្បៀងអាហារប្រចាំនៅតំបន់អាស៊ី | ( PCFS ) |
| ៦១. សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ | ( IDEA ) |
| ៦២. សហព័ន្ធសហជីពកម្មករចំណីអាហារ និងសេវាកម្មកម្ពុជា | ( CFSWF ) |
| ៦៣. សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា | ( អាដហុក ) |
| ៦៤. សហព័ន្ធសហជីពឯករាជ្យ | ( អ៊ីនទូហ្វី ) |
| ៦៥. សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើល | ( LRSU ) |
| ៦៦. សហព័ន្ធសហជីពកម្ពុជា | ( កាទូ ) |
| ៦៧. សហព័ន្ធសហជីពកម្មករនិយោជិតវិស័យទេសចរណ៍កម្ពុជា | ( CTWUF ) |
| ៦៨. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា | ( BWTUC ) |
| ៦៩. សមាគមកម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ | ( CIWA ) |
| ៧០. សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស | ( លីកាដូ ) |
| ៧១. សម្ព័ន្ធប្រជានេសាទកម្ពុជា | ( CCF ) |
| ៧២. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា | ( CID ) |
| ៧៣. វិទ្យាស្ថានសិក្សាស្រាវ និងអភិវឌ្ឍន៍សមត្ថភាព | ( The CamNature ) |
| ៧៤. អង្គការសមធម៌កម្ពុជា | ( EC ) |
| ៧៥. អង្គការសមាគមធាងត្នោត | ( STT ) |
| ៧៦. អង្គការពន្លកខ្មែរ | ( PKH ) |
| ៧៧. អង្គការពន្លឺនៃក្ដីសង្ឃឹម | ( PNKS ) |
| ៧៨. អង្គការអនុផលព្រៃឈើ | ( NTFP ) |

៧៩. អង្គការគណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា( ខុមហ្វ្រែល )
៨០. អង្គការកម្មវិធីអភិវឌ្ឍន៍ធនធានយុវជន (YRDP)
៨១. អង្គការសម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា (ANSA)
៨២. អង្គការស្ពានសន្តិភាព (PBO)
៨៣. អង្គការសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA)
៨៤. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)
៨៥. អង្គការស្ម័គ្រចិត្តដើម្បីសង្គម (CVS)
៨៦. អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT)
៨៧. អង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់ (ACT)

**អ្នកចូលរួមគាំទ្រឯកជនៈ**

១. អ្នកស្រី ឈឹម ចាន់នាង អ្នកសម្របសម្រួលនៃ NGO-CEDAW
២. លោក ពុត កុលកា សកម្មជនសង្គម